



# ការបង្វិលសងពន្ធសម្រាប់កម្មករទីក្រុង Washington!

Working Families Tax Credit (ឥណទានពន្ធសម្រាប់គ្រួសារដែលមានការងារ) ងារនឹងផ្តល់ការបង់ប្រាក់រហូតដល់ $1,290 សម្រាប់ឆ្នាំពន្ធ 2024 ដល់បុគ្គល និងគ្រួសារដែលបំពេញតាមលក្ខខណ្ឌ។

**តើអ្នកណាមានសិទ្ធិទទួលបានការបង្វិលសងពន្ធ ?**

បុគ្គល និងគ្រួសារមានសិទ្ធិទទួលបាន ប្រសិនបើពួកគេបំពេញតាមលក្ខខណ្ឌទាំងអស់ខាងក្រោម៖

- រស់នៅទីក្រុង Washington យ៉ាងហោចណាស់ 183 ថ្ងៃ។
- មានអាយុយ៉ាងតិច 25 ឆ្នាំ និងក្រោម 65 ឆ្នាំ ឬមាន កូនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅឆ្នាំ 2024។
- បានដាក់លិខិតប្រកាសពន្ធសហព័ន្ធឆ្នាំ 2024 ជាមួយនឹងលេខសន្តិសុខសង្គម (Social Security Number, SSN) ឬលេខអត្តសញ្ញាណកម្មសារពើពន្ធរូបវន្តបុគ្គល (Individual Taxpayer Identification Number, ITIN)។
- មានសិទ្ធិទទួលបានឥណទានពន្ធលើប្រាក់ចំណូលដែលរកបានរបស់សហព័ន្ធនៅលើលិខិតប្រកាសពន្ធឆ្នាំ 2024 របស់ពួកគេ។
  – ចូលទៅកាន់ www.irs.gov/eitc ដើម្បីស្វែងយល់បន្ថែម។
- បំពេញលក្ខខណ្ឌប្រាក់ចំណូល (សូមមើលតារាង)។

**តើបុគ្គល និងគ្រួសារនឹងបានប្រាក់ប៉ុន្មានត្រឡប់ទៅវិញ?**

វាអាស្រ័យលើចំនួនកុមារដែលមានសិទ្ធិទទួលបាន និងកម្រិតប្រាក់ចំណូល។ សូមមើលតារាងសម្រាប់ការប៉ាន់ស្មានដោយផ្អែកលើកម្រិតនៃសិទ្ធិទទួលបានប្រាក់ចំណូលឆ្នាំ 2024។

**តើកម្រិតចំណូលមានប៉ុន្មានដែរ?**

| ចំនួនកុមារដែលមានសិទ្ធិទទួលបាន | អ្នកដាក់ពាក្យត្រូវតែរកប្រាក់បានតិចជាងខាងក្រោម | | ប្រាក់បង្វិលមកវិញជាអតិបរមា |
|---|---|---|---|
| | នៅលីវ | រៀបការ *(ការដាក់ឯកសាររួមគ្នា)* | |
| 0 | $18,591 | $25,511 | $325 |
| 1 | $49,084 | $56,004 | $640 |
| 2 | $55,768 | $62,688 | $965 |
| 3 *ឬច្រើនជាងនេះ* | $59,899 | $66,819 | $1,290 |

ដាក់ពាក្យឥឡូវនេះតាមរយៈ WFTC.wa.gov/apply។

ដើម្បីទទួលបានព័ត៌មានបន្ថែម ឬចុះឈ្មោះសម្រាប់ព័ត៌មានថ្មីៗ សូមចូលទៅកាន់គេហទំព័ររបស់យើង៖ WFTC.wa.gov ឬហៅទូរសព្ទទៅលេខ 360-763-7300។

WFTC0001-KH 12/16/2024

Department of Revenue Washington State